ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អអក

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ០៦៤ ស ៣ ១៧ អអក

ភ្នំពេញ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# ស្តីពីការពិគ្រោះយោបល់សាធារណៈលើសេចក្តីព្រាងអាជ្ញាបណ្ណរបស់ លោកស្រី អេន ចន្ថា សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃ ស្រុកបរិបូណ៌ និងឃុំប្រស្និប ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងស្រុកបរិបូណ៌ និងឃុំប្រស្និប ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឲ្យបានជ្រាបថា អនុវត្តតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងនឹងចេញអាជ្ញាបណ្ណឲ្យលោកស្រី អេន ចន្ថា ដែលមានប្រកាសក្រសួងរ៉ែ និងថាមពល សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកបរិបូណ៌ និងឃុំប្រស្និប ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង តាមសំណើសុំរបស់លោកស្រី អេន ចន្ថា ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការចេញអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យ ផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា លើខ្លឹមសារនៃសេចក្តីព្រាងលក្ខខណ្ឌអាជ្ញាបណ្ណ ដែលគ្រោងនឹងផ្តល់ឲ្យលោកស្រី អេន ចន្ថា ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងលក្ខខណ្ឌអាជ្ញាបណ្ណនៅ .............................................................................................................................................. សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះសូមសាធារណជនរស់នៅក្នុងស្រុកបរិបូណ៌ និងឃុំប្រស្និប ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញអាជ្ញាបណ្ណឲ្យលោកស្រី អេន ចន្ថា អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពី ថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **" អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានហេតុផលយ៉ាង ច្បាស់លាស់ប៉ុណ្ណោះ "** ។៚

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

អាជ្ញាធរអគ្គិសនីកម្ពុជា : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

សេចក្តីព្រាង

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# អាជ្ញាបណ្ណចែកចាយ
# សម្រាប់ធ្វើសេវាកម្មចែកចាយអគ្គិសនីនៅផ្នែកខ្លះនៃស្រុកបរិបូណ៌ និងឃុំប្រស្និប ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

**DISTRIBUTION LICENSE**
**FOR PROVIDING ELECTRIC POWER DISTRIBUTION SERVICE AT SOME PART OF BORIBO DISTRICT AND KHUM BROSNEB, ROLEAR PHEAR DISTRICT, KAMPONG CHHNANG PROVINCE**

## លោកស្រី អេន ចន្ថា
**MRS. EN CHANTHA**

ថ្ងៃទី ខែ ឆ្នាំ២០១៧
….. ….., 2017

# ផ្នែកទី១
# សេចក្តីសម្រេចផ្តល់សិទ្ធិឲ្យធ្វើសេវាកម្ម

# PART I

## DECISION TO GRANT THE RIGHT TO PROVIDE THE ELECTRIC POWER SERVICE